

# CAMBODIA LABOR LAW AND COMPLIANCE




ចំណេះដឹងលើច្បាប់ការងារគឺជាផ្នែកមួយដ៏សំខាន់មិនអាចខ្វះបានសម្រាប់លោកអ្នកជានាយក ថ្នាក់ដឹកនាំ ប្រធាននិងជាពិសេសអ្នកទទួលបន្ទុកផ្នែកគ្រប់គ្រងធនធានមនុស្ស នៅតាមបណ្ដាក្រុមហ៊ុន គ្រឹះស្ថានឯកជន ធនាគារ ម្ចាស់អាជីវកម្មតូចធំ និង អង្គការមិនមែនរដ្ឋាភិបាល។ វគ្គនេះត្រូវបានរៀបចំឡើងសម្រាប់និយោជិក និងនិយោជកដែលមានទំនួលខុសត្រូវ លើផ្នែកគ្រប់គ្រងធនធានមនុស្សដើម្បីរួមចំណែកក្នុងការសម្រួលនិង ដោះស្រាយលើស្ថានភាពនៃវិវាទផ្សេងៗនៅកន្លែងការងារ។ច្បាប់ការងារគឺជាមូលដ្ឋានដ៏រឹងមាំក្នុងការផ្ដល់ប្រព័ន្ធ គ្រប់គ្រងសុវត្ថិភាពការងារ និងដោះស្រាយវិវាទដោយសន្តិវិធី។លើសពីនេះទៅទៀតវគ្គនេះពិតជាមានគុណ ប្រយោជន៍ហើយផ្សារភ្ជាប់យ៉ាងខ្លាំងទៅគ្រប់ផ្នែកពាក់ព័ន្ធជាពិសេសផ្នែកគ្រប់គ្រងធនធានមនុស្សដែលទាមទារ អោយយើងត្រូវយល់ដឹងកាន់តែច្បាស់ដើម្បីជាទុនក្នុងការទប់ស្កាត់ គ្រប់គ្រងស្ថានការណ៍ និងវិវាទផ្សេងៗ ផ្អែកលើច្បាប់ការងារ។

## Course Objective

ក្រោយបញ្ចប់វគ្គបណ្ដុះបណ្ដាលសិក្ខាកាមនឹងយល់ច្បាស់អំពី:

- ☑ គោលការណ៍មូលដ្ឋាននៃច្បាប់ការងារនិងលក្ខណៈការងារនៅក្នុងប្រទេសកម្ពុជា។
- ☑ គោរពតាមបទប្បញ្ញត្តិនៃតួនាទីនិងទំនួលខុសត្រូវរបស់និយោជិកដែលមានជាអាទិ៍ ហើយផ្សារភ្ជាប់ទៅច្បាប់ការងារប្រទេសកម្ពុជា។
- ☑ ការអនុវត្តច្បាប់ការងារនិងលក្ខណៈការងារអ្នកជំនាញធនធានមនុស្ស។
- ☑ ការអនុវត្តសកម្មភាពវិន័យនិងការបណ្ដេញចេញឬការបញ្ចប់កិច្ចសន្យាស្របតាមច្បាប់ការងាររបស់កម្ពុជា។

## Course Outline

- មេរៀនទី ១៖ បទដ្ឋានស្ដីពីការងារពាក់ព័ន្ធនិងការទទួលខុសត្រូវរបស់និយោជក
- មេរៀនទី ២៖ វិធានការនានាពាក់ព័ន្ធកត្តកិច្ចរបស់និយោជក
- មេរៀនទី ៣៖ ការងារទំនាក់ទំនងវិជ្ជាជីវៈ
- មេរៀនទី ៤៖ ការដោះស្រាយវិវាទការងារ
- មេរៀនទី ៥៖ កូដកម្ម និង បាតុកម្ម
- មេរៀនទី ៦៖ ទីផ្សារការងារ និងតម្រូវការជំនាញ

## Who Should Attend?

វគ្គសិក្សានេះត្រូវបានរៀបចំឡើងសម្រាប់អ្នកគ្រប់គ្រងគ្រប់ផ្នែកជាពិសេសផ្នែកគ្រប់គ្រងធនធានមនុស្សដែលសំដៅអនុវត្តអោយមានប្រសិទ្ធភាពផ្សារភ្ជាប់ជាមួយលក្ខណៈវិនិច្ឆ័យស្ថានភាពជាក់ស្ដែងទាក់ទងទៅនឹងច្បាប់ការងារជាមូលដ្ឋានជំនួយសម្រាប់ក្រុមហ៊ុននិងអង្គការស្របតាមបទប្បញ្ញត្តិរបស់ក្រសួងការងារ។